# មេរៀនទី ១៨: ព្រះយេស៊ូវបានបង្ហាញខ្លួននៅមុខម៉ារា

## យ៉ូហាន ២០:១-១៨

**គោលបំណង៖** ព្រះយេស៊ូវមានអំណាចលើសេចក្តីស្លាប់ ហើយទ្រង់មានព្រះជន្មរស់សព្វថ្ងៃ

**ខគម្ពីរចងចាំ៖ យ៉ូហាន ១១:២៥** *"ព្រះយេស៊ូវមានព្រះបន្ទូលទៅនាងថា ខ្ញុំជាសេចក្តីរស់ឡើងវិញ ហើយជាជីវិត អ្នកណាដែលជឿដល់ខ្ញុំ ទោះបើបានស្លាប់ហើយ គង់តែនឹងរស់ឡើងវិញដែរ។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

បន្ទាប់ពីបានឃើញការអស្ចារ្យដែលមិនគួរឱ្យជឿដែលឃើញសពបុរសម្នាក់(ឡាសារ)បានរស់ឡើងវិញ ហើយបានឮការព្យាករណ៍របស់ព្រះយេស៊ូវអំពីការសុគតរបស់ទ្រង់នោះ ពួកសិស្សនៅតែមិនរំពឹងថានឹងមានទីបញ្ចប់ដ៏រីករាយចំពោះការឆ្កាងព្រះយេស៊ូវដែរ។ ការរស់ឡើងវិញរបស់ព្រះយេស៊ូវបានផ្លាស់ប្តូរអ្វីៗទាំងអស់ ហើយបានផ្តល់ឱ្យពួកសិស្សនូវភាពក្លាហាន ដែលពួកគេត្រូវការ ដើម្បីប្រឈមមុខនឹងការស្លាប់របស់ពួកគេដោយគ្មានការភ័យខ្លាច។ តើការរស់ឡើងវិញរបស់ព្រះគ្រីស្ទបានផ្លាស់ប្តូររបៀបរស់នៅរបស់អ្នកយ៉ាងដូចម្តេច? ថ្ងៃនេះ សូមចែកចាយពីអំណាច និងសេចក្តីអំណរដែលយើងអាចរកឃើញនៅក្នុងការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវជាមួយកុមារ។

**ចំរៀង៖** ១. ខ្ញុំនឹងទុកចិត្តទ្រង់ ២. ព្រះអម្ចាស់ទ្រង់ស្ថិតស្ថេរ ៣. មានទន្លេជីវិត

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត « យប់ និងថ្ងៃ»**

**សម្ភារៈដែលត្រូវការ៖** ក្រដាសរឹង ឬ ចានជ័រ (ដែលអាចបោះឡើងលើបាន)សូមសរសេរពាក្យថា "ពេលថ្ងៃ" នៅម្ខាង ហើយម្ខាងទៀត សរសេរពាក្យថា "ពេលយប់"




១. ចែកកុមារជា២ក្រុមគឺ ក្រុមថ្ងៃ និងក្រុមយប់ នៅពេលចែកក្រុមរួចហើយ យើងឲ្យក្រុមទាំងពីរឈរជាជួរបែរមុខរកគ្នា

២.គ្រូត្រូវធ្វើជាអាជ្ញាកណ្តាលរវាងក្រុមទាំង២

៣.គ្រូត្រូវកំណត់ខ្សែទីផងដែរ ហើយក្រុមដែលត្រូវគេដេញចាប់អាចរត់ហួសខ្សែទីនោះបាន ប៉ុន្តែក្រុមដែលត្រូវដេញចាប់គេមិនត្រូវរត់ហួសខ្សែទីនោះឡើយ។

៤. គ្រូបោះចានឬក្រដាសឡើងទៅលើបើចានឬក្រដាសធ្លាក់ប៉ះចំពាក្យ "ពេលថ្ងៃ" ក្រុមថ្ងៃដេញ ចាប់ក្រុម "ពេលយប់" តែបើក្រដាសឬចានធ្លាក់ប៉ះចំពាក្យ "ពេលយប់" ក្រុមយប់ត្រូវដេញចាប់ក្រុម "ពេលថ្ងៃម្តង" វិញម្តង។

បន្ទាប់ពីលេងល្បែងនេះរួចហើយ គ្រូពន្យល់សិស្សថា "ពេលយប់" គឺតំណាងឲ្យសេចក្តីស្លាប់ ហើយ"ពេលថ្ងៃ" តំណាងឲ្យការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ។

## ៤. ការណែនាំមេរៀន

តើប្អូនធ្លាប់ចូលរួមពិធីបុណ្យសពដែរឬទេ? តើអ្នកមានអារម្មណ៍យ៉ាងណានៅពេលទៅចូលរួមបុណ្យសព? តើប្អូនធ្លាប់ឃើញមានអ្នកស្លាប់ហើយអាចរស់ឡើងវិញបានដែរឬទេ? យើងទាំងអស់គ្នាដឹងហើយថា គ្មាននរណាម្នាក់មានថាមពលអាចរស់ឡើងវិញបន្ទាប់ពីពួកគេស្លាប់នោះទេ។ តែមានមនុស្សម្នាក់ដែលស្លាប់ហើយអាចរស់ឡើងវិញបាន! យើងនឹងស្វែងយល់ពីបុគ្គលដ៏ពិសេសម្នាក់នោះដែលបានសន្យាថា នឹងផ្ដល់នូវថាមពលដូចគ្នាមកឲ្យយើងរាល់គ្នាតាមរយៈគាត់!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

កាលពីសប្ដាហ៍មុន យើងបានរៀនពីព្រះយេស៊ូវបានសុគតលើឈើឆ្កាងជំនួសអំពើបាបរបស់យើង ដើម្បីឲ្យយើងអាចក្លាយជាចំណែកនៃគ្រួសាររបស់ព្រះបាន។ ក្រោយពីព្រះយេស៊ូវសុគតព្រះអង្គត្រូវគេបញ្ចុះ ទៅក្នុងផ្នូរដែលផ្នូរគឺដូចជារូងភ្នំអ៊ីចឹង។ ថ្មដ៏ធំមួយត្រូវបានគេយកមកដាក់នៅមាត់ច្រកចូល។ ក្រោយពីគេបញ្ចុះសពព្រះយេស៊ូវហើយ មិត្តរបស់ទ្រង់ទាំងអស់កើតទុក្ខយ៉ាងខ្លាំង។ ពួកគេគិតថា ពួកគេនឹងមិនអាចឃើញព្រះយេស៊ូវទៀតទេ។ ម៉ារា ម៉ាក់ដាឡា បានទៅឯផ្នូរដែលគេបានបញ្ចុះព្រះយេស៊ូវ។ នាងមានការភ្ញាក់ផ្អើលពេលនាងទៅដល់ទីនោះព្រោះដុំថ្មដ៏ធំនោះត្រូវបានរមៀលចេញពីផ្នូរ!

នាងបានរត់ទៅប្រាប់ពេត្រុស និងយ៉ូហាន ដែលជាមិត្តជិតស្និតរបស់ព្រះយេស៊ូវ។ ពេត្រុស និងយ៉ូហានរត់ត្រឡប់ទៅឯផ្នូរវិញ។ ពួកគេបានឃើញតែក្រណាត់ដែលគេរុំសពព្រះយេស៊ូវក្នុងរូងភ្នំ។ ប៉ុន្តែព្រះយេស៊ូវមិនបាននៅទីនោះទេ។ មួយសន្ទុះក្រោយមកពេត្រុស និងយ៉ូហានបានត្រឡប់ទៅផ្ទះវិញ។

ប៉ុន្តែម៉ារាបាននៅខាងក្រៅផ្នូរ ហើយអង្គុយយំនាងសោកសៅជាខ្លាំង។ បន្ទាប់មក ម៉ារាមើលទៅក្នុងផ្នូរម្ដងទៀត។ លើកនេះនាងបានឃើញទេវតាពីររូបនៅកន្លែងដែលគេទុកសពព្រះយេស៊ូវ! ទេវតាសួរម៉ារាថា ហេតុអ្វីបានជានាងយំ? ពេលនោះព្រះយេស៊ូវយាងមកពីក្រោយនាង ហើយហៅឈ្មោះរបស់នាង។ ម៉ារាបានដឹងថាជាព្រះយេស៊ូវនៅពេលដែលទ្រង់ ហៅឈ្មោះរបស់នាង! ម៉ារាសប្បាយចិត្តណាស់ ពីព្រោះព្រះយេស៊ូវបានរស់ពីសុគតឡើងវិញ! នាងបានទៅប្រាប់មិត្តភក្តិរបស់នាងអំពីព្រះយេស៊ូវ។

ដោយសារព្រះយេស៊ូវមិនបានសុគតរហូតទេ ប៉ុន្តែទ្រង់បានរស់ឡើងវិញ ហើយយើងដឹងថាទ្រង់គឺជាព្រះ! យើងដឹងថា ព្រះយេស៊ូវមានអំណាចលើសេចក្ដីស្លាប់! យើងមិនត្រូវភ័យខ្លាចអ្វីឡើយ ព្រោះអំណាចរបស់ព្រះយេស៊ូវអាចមើលថែយើង និងជួយយើងទោះបីជាអំណាច នៃសេចក្ដីស្លាប់ក៏ដោយ! ពេលយើងស្លាប់យើងនឹងមានជីវិតរស់ឡើងវិញ ហើយរស់នៅជាមួយនឹងព្រះអស់កល្បជានិច្ច!

## ៦. សំនួរពិភាក្សា

១. តើផ្នូរសំរាប់ដាក់សពនៅសម័យព្រះយេស៊ូវមានរូបរាងដូចម្ដេច?

*មានរាងដូចជារូងភ្នំដែលមានថ្មធំនៅមុខច្រកចូល*

២. តើម៉ារា ម៉ាក់ដាឡា និងពួកសិស្សរកឃើញអ្វីនៅក្នុងផ្នូរ?

*ក្រណាត់ដែលរុំព្រះសពព្រះយេស៊ូវគឺនៅទីនោះ ប៉ុន្តែព្រះយេស៊ូវមិនបាននៅទីនោះទេ*

៣. តើមានអ្វីកើតឡើងចំពោះព្រះយេស៊ូវ? *ទ្រង់មានព្រះជន្មរស់ឡើងវិញ!*

៤. ដោយសារព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ តើបានធ្វើឲ្យអ្នកមានសេចក្ដីសង្ឃឹមអ្វីខ្លះ? *យើងមានសង្ឃឹមថា សេចក្ដីស្លាប់មិនមែនជាទីបញ្ចប់សម្រាប់យើងនោះទេ។ យើងនឹងមានជីវិតរស់ឡើងវិញ ហើយរស់នៅជាមួយនឹងព្រះអស់កល្បជានិច្ច*

## ៧. ល្បែងកំសាន្ត « ផ្ទុះបំបែកសារ! »

**សម្ភារៈដែលត្រូវការ៖** ក្រដាសដែលមានសរសេរសារ (សូមមើលខាងក្រោមដើម្បីបោះពុម្ព) ប៉េងប៉ោង

| | |
|---|---|
| ទ្រង់មានព្រះជន្មរស់ឡើងវិញពិតប្រាកដមែន! | ព្រះយេស៊ូវនៅមានព្រះជន្មរស់! |
| ព្រះយេស៊ូវសុគតសំរាប់អំពើបាបយើង! | ព្រះគ្រីស្ទជាព្រះដែលមានព្រះជន្មរស់ឡើងវិញដល់សព្វថ្ងៃនេះ! |
| សរសើរដំកើងព្រះ! ផ្នូរទទេ! | ខ្ញុំអាចទៅស្ថានសួគ៌បាន ដោយសារព្រះយេស៊ូវមានព្រះជន្មរស់! |
| ទ្រង់មានព្រះជន្មរស់ឡើងវិញដូចទ្រង់មានបន្ទូល! | ជឿលើអំណាចនៃការរស់ឡើងវិញ! |
| ចេញពីផ្នូរ ទ្រង់បានរស់ឡើងវិញ! | ព្រះគ្រីស្ទបានរស់ឡើងវិញ! ស្រែកឡើង "ហូសាណា!" |



១. មុនពេលកុមារចូលមកក្នុងថ្នាក់រៀន សូមរៀបចំដាក់ក្រដាសសារទៅក្នុងប៉េងប៉ោង ហើយផ្លុំឲ្យប៉ោង។

២. ពន្យល់កុមារថា សូមចាត់ទុកប៉េងប៉ោងដូចជាផ្នូរដែលព្រះយេស៊ូវត្រូវបានគេយកទៅបញ្ចុះ។ នៅពេលដែលពួកសិស្សមកពួកគេមិនឃើញព្រះសពរបស់ព្រះយេស៊ូវនៅក្នុងផ្នូរទេ។ពួកគេឃើញតែក្រណាត់ដែលរុំព្រះសពរបស់ទ្រង់តែប៉ុណ្ណោះ។ នេះដូចជាការរំឭកផងដែរថា ព្រះយេស៊ូវគង់នៅទីនោះ។ នៅខាងក្នុងប៉េងប៉ោងនីមួយៗ អ្នកឃើញមានសារដែលរំឭកអ្នកអំពីព្រះយេស៊ូវ



៣. ឲ្យប៉េងប៉ោង ទៅកុមារម្នាក់មួយៗ ហើយឱ្យពួកគេបំបែកប៉េងប៉ោងនោះ ដើម្បីស្វែងរកសាររំលឹកពួកគេអំពីព្រះយេស៊ូវ។

៤. ពេលគេរកឃើញសារនេះហើយគេត្រូវស្រែកប្រាប់អ្នករាល់គ្នា!

## ៨. ខគម្ពីរចងចាំ យ៉ូហាន ១១:២៥

## ៩. ហត្ថកម្ម «ផាត់ពណ៌ - ព្រះយេស៊ូវបានបង្ហាញខ្លួននៅមុខម៉ារា»

សូមបោះពុម្ពរូបភាព ដើម្បីឲ្យកុមារផាត់ពណ៌ ហើយឱ្យពួកគេសរសេរខគម្ពីរចងចាំនៅលើក្រដាសនោះ។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# បំបែកសារ

| | |
|---|---|
| ទ្រង់មានព្រះជន្មរស់ឡើងវិញពិតប្រាកដមែន! | ព្រះយេស៊ូវនៅមានព្រះជន្មរស់! |
| ព្រះយេស៊ូវសុគត សំរាប់អំពើបាបយើង! | ព្រះគ្រីស្ទជាព្រះដែលមានព្រះជន្មរស់ឡើងវិញដល់សព្វថ្ងៃនេះ! |
| សរសើរដំកើងព្រះ! ផ្នូរទទេ! | ខ្ញុំអាចទៅស្ថានសួគ៌បាន ដោយសារព្រះយេស៊ូវមានព្រះជន្មរស់! |
| ទ្រង់មានព្រះជន្មរស់ឡើងវិញដូចទ្រង់មានបន្ទូល! | ជឿលើអំណាចនៃការ រស់ឡើងវិញ! |
| ចេញពីផ្នូរ ទ្រង់បានរស់ឡើងវិញ! | ព្រះគ្រីស្ទបានរស់ឡើងវិញ! ស្រែកឡើង “ហូសាណា!” |

# ព្រះយេស៊ូវបានបង្ហាញខ្លួននៅមុខម៉ារា



សូមសរសេរខគម្ពីរចងចាំ:______________________________

______________________________________________

______________________________________________